CAO COMPLIANCE ADVISOR OMBUDSMAN

*The Independent Accountability Mechanism for IFC & MIGA*

# របាយការណ៍វាយតម្លៃរបស់ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ)

## អំពីកង្វល់ពាក់ព័ន្ធនឹងការវិនិយោគរបស់ IFC នៅក្នុងធនាគារ Postal Savings Bank of China (គម្រោង IFC លេខ ៣៥៤៦១)

ខែឧសភា ឆ្នាំ២០២៤

ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ

*សម្រាប់*

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និង

ទីភ្នាក់ងារធានាការវិនិយោគពហុភាគី

**www.cao-ombudsman.org**

## អំពីស៊ីអេអូ

ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) គឺជាយន្តការគណនេយ្យភាពឯករាជ្យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និង ទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសមាជិកក្រុមធនាគារពិភពលោក។ យើងធ្វើការសម្របសម្រួលដោះស្រាយបណ្តឹងពីប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់ពីគម្រោងរបស់ IFC និង MIGA ដោយយុត្តិធម៌ ឥតលម្អៀង និងប្រកបដោយភាពស្ថាបនា លើកកម្ពស់លទ្ធផលផ្នែកបរិស្ថាន និងសង្គមនៃគម្រោងទាំងនោះ និងបង្កើនគណនេយ្យភាពសាធារណៈ និង ការរៀនសូត្រនៅ IFC និង MIGA។

ស៊ីអេអូ រាយការណ៍ទៅកាន់ក្រុមប្រឹក្សានាយកប្រតិបត្តិការរបស់ IFC និង MIGA ដោយផ្ទាល់។ សម្រាប់ព័ត៌មានបន្ថែម សូមមើល៖ www.cao-ombudsman.org។

## អំពីការវាយតម្លៃរបស់ស៊ីអេអូ

បុគ្គល ដែលជឿថាពួកគេអាចរងគ្រោះថ្នាក់ដោយសារគម្រោង IFC ឬ MIGA អាចដាក់ពាក្យបណ្តឹងទៅកាន់ស៊ីអេអូបាន។ យើងអនុវត្តលក្ខណវិនិច្ឆ័យអំពីលក្ខខណ្ឌសមស្របដ៏សាមញ្ញចំនួនបី ដើម្បីទទួលយកពាក្យបណ្តឹង។ ចំពោះពាក្យបណ្តឹងដែលមានលក្ខខណ្ឌសមស្រប យើងវាយតម្លៃអំពីកង្វល់នានាជាមួយដើមបណ្តឹង អ្នកឧបត្ថម្ភគម្រោង និងភាគីពាក់ព័ន្ធដទៃទៀត។

នៅពេលដែលពាក្យបណ្តឹងត្រូវបានកំណត់ថាមានលក្ខខណ្ឌសមស្របហើយនោះ យើងត្រួតពិនិត្យឡើងវិញលើកង្វល់ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងនោះ។ ការវាយតម្លៃនេះធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយដើមបណ្តឹង អតិថិជនរបស់ IFC និង MIGA និងក្រុមការងារផ្នែកគម្រោង និងភាគីពាក់ព័ន្ធដទៃទៀត។

## គោលបំណង

គោលបំណងនៃដំណើរការវាយតម្លៃរបស់ស៊ីអេអូគឺ ដើម្បីបង្កើតការយល់ដឹងឱ្យបានហ្មត់ចត់អំពីបញ្ហាដែលពាក្យបណ្តឹងបានលើកឡើង ធ្វើការស្វែងយល់អំពីទស្សនៈទាំងអស់ ចូលរួមជាមួយរាល់ភាគីសំខាន់ៗដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង ពិគ្រោះយោបល់ជាមួយពួកគេ ដើម្បីកំណត់ដំណើរការដែលពួកគេជ្រើសរើស ដើម្បីដោះស្រាយពាក្យបណ្តឹង និងពិចារណាអំពីស្ថានភាពនៃកិច្ចខិតខំប្រឹងប្រែងដោះស្រាយបណ្តឹងសារទុក្ខផ្សេងទៀត ដែលបានធ្វើឡើង ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើង។

# មាតិកា

មាតិកា ..... III

អក្សរកាត់ ..... IV

1. ទិដ្ឋភាពទូទៅ ..... 1

2. សាវតា ..... 2

    2.1 គម្រោង ..... 2

    2.2 ពាក្យបណ្ដឹង ..... 2

3. សេចក្ដីសង្ខេបអំពីការវាយតម្លៃ ..... 3

    3.1 វិធីសាស្ត្រ ..... 3

    3.2 សេចក្ដីសង្ខេបអំពីទស្សនៈ ..... 4

4. សេចក្ដីសន្និដ្ឋានអំពីការវាយតម្លៃ ..... 9

ឧបសម្ព័ន្ធ ក. ដំណោះស្រាយដោះស្រាយពាក្យបណ្ដឹងរបស់ស៊ីអេអូ ..... 11

# អក្សរកាត់

| | |
|---|---|
| ស៊ីអេអូ | ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (IFC និង MIGA) |
| E&S | បរិស្ថាន និងសង្គម |
| FI | អន្តរការីហិរញ្ញវត្ថុ |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| MIGA | ទីភ្នាក់ងារធានាការវិនិយោគពហុភាគី |
| PRC | សាធារណរដ្ឋប្រជាមានិតចិន |
| PSBC | ធនាគារ Postal Savings Bank of China |

## 1. ទិដ្ឋភាពទូទៅ

នៅខែសីហា ឆ្នាំ២០២៣ ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ (ស៊ីអេអូ) បានទទួលពាក្យបណ្តឹងទាក់ទងនឹងផលប៉ះពាល់សង្គម និងបរិស្ថាន នៃគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម ២ ("គម្រោងសេសានក្រោម ២") នៅប្រទេសកម្ពុជា។ ពាក្យបណ្តឹងនេះបានចោទប្រកាន់ថា IFC បានផ្តល់កម្ចីដល់គម្រោងសេសានក្រោម តាមរយៈការវិនិយោគរបស់ខ្លួននៅក្នុងធនាគារ Postal Savings Bank of China (PSBC)។

នៅខែវិច្ឆិកា ឆ្នាំ២០២៣ ស៊ីអេអូ បានកំណត់ថា ពាក្យបណ្តឹងបានបំពេញតាមលក្ខណវិនិច្ឆ័យអំពីលក្ខខណ្ឌសមស្របទាំងបីរបស់ខ្លួន និងបានចាប់ផ្តើមធ្វើការវាយតម្លៃលើពាក្យបណ្តឹងនោះ។[1] នៅខែមីនា ឆ្នាំ២០២៤ ស្របតាមកថាខណ្ឌទី ៥៦ (២) នៃគោលនយោបាយស៊ីអេអូ គណៈគ្រប់គ្រងស៊ីអេអូ បានធ្វើការពន្យារពេលការវាយតម្លៃរហូតដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤។

ក្នុងអំឡុងពេលវាយតម្លៃ ដើមបណ្តឹងបានបង្ហាញអំពីចំណាប់អារម្មណ៍របស់ពួកគេចំពោះការចូលរួមក្នុងកិច្ចពិភាក្សាសម្របសម្រួលជាមួយម្ចាស់គម្រោងសេសានក្រោម ២។ PSBC បានសម្តែងការមិនយល់ស្របចំពោះការសម្រេចចិត្តអំពីលក្ខខណ្ឌសមស្របរបស់ស៊ីអេអូ និងបានអះអាងថា ពុំមានការបំពេញស្របតាមលក្ខខណ្ឌតម្រូវនៃមាត្រា ៤១ (ក) នៃគោលនយោបាយស៊ីអេអូ[2] ទេ។ ស្របពេលជាមួយគ្នានេះ ពួកគេបានពន្យល់ថា ពួកគេនឹងមិនជំទាស់នឹងស៊ីអេអូ ដែលសម្របសម្រួលដំណើរការកិច្ចសន្ទនា ក្នុងគោលបំណងដោះស្រាយបញ្ហានៃពាក្យបណ្តឹងនោះទេ។ ពួកគេបានចង្អុលបង្ហាញថា ពួកគេមិនមែនជាសមភាគីដ៏ត្រឹមត្រូវសម្រាប់រឿងនេះទេ ប៉ុន្តែមិនបានជំទាស់នឹងស៊ីអេអូ ក្នុងការទាក់ទងម្ចាស់គម្រោង ដើម្បីស្វែងរកចំណាប់អារម្មណ៍របស់ពួកគេដែលអាចមាន ចំពោះការចូលរួមក្នុងដំណើរការនោះជាមួយដើមបណ្តឹងនោះឡើយ។ ស៊ីអេអូ បានព្យាយាមទាក់ទងជាច្រើនដងទៅក្រុមហ៊ុន Huaneng Lancang River International Energy ដែលគេចោទថាជាម្ចាស់ភាគហ៊ុនធំនៃគម្រោងសេសានក្រោម ២ (ម្ចាស់គម្រោង) ប៉ុន្តែមិនបានជោគជ័យទេ។ ដូច្នេះ និងយោងតាមគោលនយោបាយ ស៊ីអេអូ សំណុំរឿងនេះនឹងបន្តទៅការវាយតម្លៃភាពអនុលោម ដែលនឹងកំណត់ថាតើពាក្យបណ្តឹងនេះសមស្របដើម្បីធ្វើការស៊ើបអង្កេតភាពអនុលោមដែរឬទេ ឬថាតើ ស៊ីអេអូ អាចបិទសំណុំរឿងនេះបានដែរឬយ៉ាងណា។

[1] ពាក្យបណ្តឹងត្រូវបានកំណត់ថាមានលក្ខខណ្ឌសមស្រប ដោយសារតែ (១) បញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង មានភាពពាក់ព័ន្ធទៅនឹងអាណត្តិការងាររបស់ ស៊ីអេអូ ក្នុងការដោះស្រាយផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមរបស់គម្រោង IFC/MIGA (២) ដើមបណ្តឹងអាចរងផលប៉ះពាល់ដោយសារគ្រោះថ្នាក់ដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង និង (៣) ពាក្យបណ្តឹងទាក់ទងទៅនឹងគម្រោងមួយដែលសកម្មរបស់ IFC។ ចាប់តាំងពីពេលដែលកំណត់ថាបណ្តឹងមានលក្ខខណ្ឌសមស្រប PSBC បានផ្តល់ឯកសារបន្ថែមជូនទៅ ស៊ីអេអូ ពាក់ព័ន្ធនឹងទំនាក់ទំនងហិរញ្ញវត្ថុរបស់ខ្លួនទៅនឹងគម្រោងសេសានក្រោម ២ នេះ។ វាស្ថិតនៅក្រៅអាណត្តិរបស់ក្រុមការងាររបស់ ស៊ីអេអូ ក្នុងការវាយតម្លៃបន្ថែមទៅលើទំនាក់ទំនងហិរញ្ញវត្ថុរវាង IFC, PSBC និងគម្រោងសេសានក្រោម ២។ ឯកសារទាំងនេះ និងឯកសារដទៃទៀត ដែលអាចចែករំលែកជាមួយ ស៊ីអេអូ នឹងត្រូវបានយកមកវាយតម្លៃបន្ថែមនៅក្នុងដំណាក់កាលវាយតម្លៃភាពអនុលោម ដែលធ្វើឡើងដោយការិយាល័យ ស៊ីអេអូ។

[2] សូមមើលគោលនយោបាយស៊ីអេអូនៅទីនេះ៖ https://www.cao-ombudsman.org/sites/default/files/documents/CAO%20Policy/ifc-miga-independent-accountability-mechanism-cao-policy.pdf

របាយការណ៍វាយតម្លៃនេះផ្តល់ទិដ្ឋភាពទូទៅអំពីដំណើរការវាយតម្លៃ រួមទាំងសេចក្តីពណ៌នាអំពីគម្រោង ពាក្យបណ្តឹង វិធីសាស្ត្រវាយតម្លៃ ទស្សនៈរបស់ដើមបណ្តឹង និង PSBC និងជំហានបន្ទាប់។

## 2. សាវតា

### 2.1 គម្រោង

យោងតាមការបង្ហាញរបស់ IFC បានឱ្យដឹងថា IFC បានធ្វើការវិនិយោគភាគហ៊ុនទៅលើ PSBC ចំនួន ២៨៦ លានដុល្លារអាមេរិក ដែលស្មើនឹង ០,៦៩% នៃភាគហ៊ុន កាលពីខែធ្នូ ឆ្នាំ២០១៥ នៅពេលដែល PSBC ប្រកាសផ្សព្វផ្សាយអំពីការផ្តល់ជូនបុរេបឋមជាសាធារណៈ ("IPO") ការទុកដាក់ភាគហ៊ុនឯកជនទៅបេក្ខភាពដែលបានសម្រាំងជ្រើសរើសនៅក្នុងបញ្ជីខ្លី នៃអ្នកវិនិយោគយុទ្ធសាស្ត្រអន្តរជាតិ និងក្នុងស្រុក រួមទាំង IFC ផងដែរ។ IFC និង PSBC ក៏បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាយុទ្ធសាស្ត្រផងដែរ ដែលកិច្ចព្រមព្រៀងនេះបានកំណត់អំពីវិស័យការងារដែល IFC នឹងផ្តល់សេវាប្រឹក្សាយោបល់ជូនទៅ PSBC។[3]

PSBC គឺជាធនាគារពាណិជ្ជធំជាងគេលំដាប់លេខរៀងទី៥ នៃសាធារណរដ្ឋប្រជាមានិតចិន បើនិយាយអំពីទ្រព្យសម្បត្តិសរុប និងធំជាងគេលំដាប់លេខរៀងទី៥ បើនិយាយអំពីប្រាក់តម្កល់សរុប គិតត្រឹមខែធ្នូ ឆ្នាំ២០២៣។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ PSBC មានទីតាំងធ្វើធុរកិច្ចសរុបចំនួន ៣៩.៣៦៤ កន្លែង ដោយគ្របដណ្តប់គ្រប់ទីក្រុងទាំងអស់ និង៩៩% នៃខោនធីទាំងអស់នៅក្នុងប្រទេសចិន ព្រមទាំងមានមូលដ្ឋានអតិថិជនលក់រាយជាង ៦៦០លាន។

ក្នុងខែធ្នូ ឆ្នាំ២០២៣ IFC បានដកខ្លួនទាំងស្រុងចេញពី PSBC ក្រោយពីបានបន្តអនុវត្តផែនការលក់មួយដែលបានទទួលការអនុម័តជាមុន។

### 2.2 ពាក្យបណ្តឹង

ពាក្យបណ្តឹងនេះត្រូវបានដាក់ក្នុងខែសីហា ឆ្នាំ ២០២៣ ដោយអង្គការមិនមែនរដ្ឋាភិបាលចំនួនបី – អង្គការទន្លេអន្តរជាតិ អង្គការឃ្លាំមើលទន្លេមេគង្គ និងគម្រោងគណនេយ្យភាពអន្តរជាតិ – តាងនាមឲ្យដើមបណ្តឹង និងដោយមានការយល់ព្រមពីពួកគេ។ ដើមបណ្តឹងរួមមាន៖

- អ្នកភូមិស្រែគរ "ចាស់" និងភូមិក្បាលរមាស "ចាស់" ដែលនៅជាប់អាងស្តុកទឹក និងបានបដិសេធមិនផ្លាស់ទៅកន្លែងតាំងលំនៅថ្មីរបស់គម្រោង។
- សហគមន៍រស់នៅតាមដងទន្លេសេសាន និងស្រែពក នៅចរន្តខ្សែទឹកខាងលើនៃអាងស្តុកទឹកគម្រោងសេសានក្រោម ២ ស្ថិតក្នុងភូមិលំផាត់ ឃុំជ័យឧត្តម និងភូមិលោមលែង ឃុំម៉ាលិក និង
- សមាជិកសហគមន៍ដែលរស់នៅកន្លែងតាំងទីលំនៅថ្មីរបស់គម្រោង។

(ចាប់ពីពេលនេះតទៅ សំដៅហៅកាត់ថា "ដើមបណ្តឹង")។

---

[3] https://disclosures.ifc.org/project-detail/SII/35461/psbc-equity

ដើមបណ្តឹងបានស្នើសុំឲ្យ ស៊ីអេអូ រក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់ ដោយភ័យខ្លាចការសងសឹក។

ពាក្យបណ្តឹងនេះបង្កអំពីកង្វល់ទាក់ទងនឹងផលប៉ះពាល់សង្គម និងបរិស្ថាន ទាក់ទងនឹងគម្រោងសេសានក្រោម ២ ដែលត្រូវបានពណ៌នាបន្ថែមនៅខាងក្រោម។

នេះគឺជាពាក្យបណ្តឹងទី២ ដែលការិយាល័យ ស៊ីអេអូ បានទទួលពីសហគមន៍ដដែល ពាក់ព័ន្ធនឹងគម្រោងសេសានក្រោម ២។ ពាក្យបណ្តឹងលើកដំបូង ទាក់ទងទៅនឹងការវិនិយោគរបស់ IFC ទៅលើធនាគារ ABBank និង Vietinbank និងបច្ចុប្បន្នកំពុងស្ថិតក្រោមការស៊ើបអង្កេតទៅលើភាពអនុលោម។[4]

## 3. សេចក្តីសង្ខេបអំពីការវាយតម្លៃ

### 3.1 វិធីសាស្រ្ត

រូបភាពទី១ ខាងក្រោមបង្ហាញអំពីអភិក្រម និងវិធីសាស្រ្ត ដែលនឹងត្រូវអនុវត្តនៅក្នុងដំណើរការវាយតម្លៃរបស់ស៊ីអេអូ។

[4] សូមមើលគេហទំព័រសំណុំរឿងរបស់ស៊ីអេអូនៅទីនេះ៖ https://www.cao-ombudsman.org/cases/cambodia-financial-intermediaries-01-03. បណ្តឹងនោះទាក់ទងទៅនឹងអនុគម្រោងដដែល ពោលគឺគម្រោងសេសានក្រោម ២ ប៉ុន្តែជាអតិថិជន និងគម្រោងរបស់ IFC ផ្សេងទៀត។

រូបភាពទី១. ដំណើរការវាយតម្លៃរបស់ស៊ីអេអូ




ដំណើរការនេះមិនបញ្ជាក់អំពីការវិនិច្ឆ័យលើអង្គសេចក្តីនៃពាក្យបណ្តឹងនោះទេ ផ្ទុយទៅវិញ វាព្យាយាមស្វែងយល់អំពីការពិត និងជួយភាគីពាក់ព័ន្ធធ្វើការសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់អំពីរបៀបដោះស្រាយបញ្ហាដែលបានលើកឡើង។

## 3.2 សេចក្តីសង្ខេបអំពីទស្សនៈ

### *ទស្សនៈរបស់ដើមបណ្តឹង*

*ការចោទប្រកាន់ថា IFC មានទំនាក់ទំនងដោយប្រយោលទៅនឹងគម្រោងសេសានក្រោម ២*

ពាក្យបណ្តឹងនេះបានចោទប្រកាន់ថា PSBC ដែលជាអតិថិជនរបស់ IFC មានទំនាក់ទំនងទៅនឹងគម្រោងសេសានក្រោម ២ តាមរយៈទំនាក់ទំនងហិរញ្ញវត្ថុ – រួមទាំងប្រាក់កម្ចីផងដែរ – ជាមួយក្រុមហ៊ុន Huaneng Lancang River Hydropower និងក្រុមហ៊ុនមេចុងក្រោយរបស់ខ្លួនគឺ China Huaneng Group Co., Ltd។ គម្រោងសេសានក្រោម ២ ចំនួន ៥១% ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន Huaneng Lancang River International Energy ដែលគ្រប់គ្រងទាំងស្រុងដោយក្រុមហ៊ុន Huaneng Lancang River Hydropower។ ពាក្យបណ្តឹងនេះបានចោទប្រកាន់បន្ថែមទៀតថា China Huaneng Group និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុននេះ បានផ្តល់ហិរញ្ញប្បទាន និងលិខិតធានាបន្ថែមទៀត ដល់គម្រោងនេះ។

យោងតាមពាក្យបណ្តឹង IFC បានខកខានក្នុងការអនុលោមតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការត្រួតពិនិត្យឱ្យបានគ្រប់គ្រាន់លើហានិភ័យផ្នែកបរិស្ថាន និងសង្គម ដែលទាក់ទងនឹងសកម្មភាពអាជីវកម្មរបស់ PSBC មុនពេលធ្វើការវិនិយោគរបស់ខ្លួន ឬតាមដានភាពអនុលោមតាមរបស់ PBSC ចំពោះលក្ខខណ្ឌតម្រូវផ្នែកបរិស្ថាន និងសង្គម (E&S) របស់ខ្លួន។

*កង្វះខាតការពិគ្រោះយោបល់ដ៏ត្រឹមត្រូវ*

យោងតាមពាក្យបណ្តឹង ការសាងសង់អាងស្តុកទឹករបស់គម្រោងសេសានក្រោមបានបណ្តាលឱ្យមានការផ្លាស់ទីលំនៅរបស់ប្រជាជនប្រមាណ ៥.០០០ នាក់ ដែលភាគច្រើនជាជនជាតិដើមភាគតិច និងជាតិពន្ធុភាគតិច។ ដើមបណ្តឹងចោទប្រកាន់ថា ពួកគេមិនបានទទួលការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ក្នុងអំឡុងពេលធ្វើផែនការ និងដំណើរការអភិវឌ្ឍន៍នៃគម្រោងនោះទេ និងថា ពុំមានការស្នើសុំការយល់ព្រមជាមុនដោយសេរី និងដោយមានព័ត៌មានគ្រប់គ្រាន់ពីពួកគេនោះទេ។

*កង្វល់ផ្នែកបរិស្ថាន និងសង្គម ទាក់ទងនឹងគម្រោងសេសានក្រោម ២*

ពាក្យបណ្តឹងបង្ហាញថា ដើមបណ្តឹងបានដាក់ពាក្យបណ្តឹងច្បាប់ដើមទៅកាន់ ស៊ីអេអូ កាលពីខែមិថុនា ឆ្នាំ ២០១៨[5] ទាក់ទងនឹងការវិនិយោគ FI របស់ IFC នៅក្នុងធនាគារ An Binh Commercial Joint Stock Bank និង VietinBank ហើយថាពាក្យបណ្តឹងនេះកំពុងស្ថិតក្នុងដំណើរការស៊ើបអង្កេតភាពអនុលោម។ ដើមបណ្តឹងបានស្នើសុំបញ្ចូលការប៉ះពាល់ដល់បរិស្ថាន និងសង្គម កង្វល់ និងសំណើរបស់សហគមន៍ ដែលបានផ្តល់ជូននៅក្នុងបណ្តឹងដើម ឆ្នាំ២០១៨ ទៅក្នុងពាក្យបណ្តឹងបច្ចុប្បន្នរបស់ពួកគេ។

ដើមបណ្តឹងបានពន្យល់បន្ថែមថា ការសាងសង់គម្រោងសេសានក្រោម ២ នេះបានធ្វើឱ្យប្រជាជនរាប់រយគ្រួសារផ្លាស់ទីលំនៅទៅកន្លែងតាំងទីលំនៅថ្មីដែលបានកំណត់ នៅខណៈពេលដែលប្រជាជនជាងមួយរយគ្រួសារនៅក្នុងភូមិចំនួនបី (ភូមិស្រែគរទី១ និង ទី២ និងភូមិក្បាលរមាស) បដិសេធមិនទទួលយកសំណងរបស់គម្រោង និងធ្វើការផ្លាស់ទីលំនៅនោះទេ។ ក្រុមដើមបណ្តឹង រួមមាន ប្រជាជនដែលរស់នៅក្នុងសហគមន៍ផ្នែកខាងលើនៃគម្រោង នៅកន្លែងតាំងទីលំនៅថ្មី និងនៅក្នុងភូមិដែលបដិសេធមិនព្រមតាំងទីលំនៅថ្មី។

ដើមបណ្តឹងបានបញ្ចេញមតិថា ពួកគេបានប្រឈមមុខនឹងផលប៉ះពាល់ផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ចាប់តាំងពីប្រតិបត្តិការគម្រោងសេសានក្រោមបានចាប់ផ្តើម ដែលរួមមាន៖

- <u>ការដាក់កម្រិតលើសកម្មភាពនេសាទ៖</u> ដើមបណ្តឹងបានបង្ហាញថា មានការលំបាកក្នុងការធ្វើសកម្មភាពនេសាទ ដោយសារការថយចុះនៃចំនួនត្រី ការថយចុះនៃលទ្ធភាពចេញចូលទន្លេ ដោយសារការផ្លាស់ទីលំនៅ និងការកើនឡើងនៃការប្រកួតប្រជែងជាមួយអ្នកនេសាទដែលកំពុងចូលមក ដែលនៅពេលខ្លះ ធ្វើការនេសាទខុសច្បាប់នៅក្នុងអាងទន្លេ។ យោងតាមដើមបណ្តឹង ការថយចុះនៃចំនួនត្រីមិនត្រឹមតែប៉ះពាល់ដល់ប្រាក់ចំណូលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគំរាមកំហែងដល់សន្តិសុខស្បៀងរបស់ពួកគេទៀតផង។
- <u>ទឹកជំនន់៖</u> យោងតាមពាក្យបណ្តឹង អ្នកភូមិនៅភាគខាងលើនៃខេត្តរតនគិរី មានកង្វល់អំពីភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃទឹកជំនន់។ ពាក្យបណ្តឹងកត់សំគាល់ថា នៅពេលដែលសហគមន៍លិចទឹក អ្នកភូមិត្រូវផ្លាស់ទីលំនៅបណ្តោះអាសន្ន ទៅរស់នៅក្នុងតង់ ធ្វើឱ្យមនុស្សចាស់ ស្ត្រីមានផ្ទៃពោះ និងកុមារងាយរងគ្រោះដល់សុខភាព និងរាងកាយ។ លើសពីនេះទៀត យោងតាមពាក្យបណ្តឹង ទឹកជំនន់ធ្វើឱ្យ

[5] សូមមើលគេហទំព័រសំណុំរឿងរបស់ស៊ីអេអូនៅទីនេះ៖ https://www.cao-ombudsman.org/cases/cambodia-financial-intermediaries-01-03

ខូចខាតដល់ស្រែ និងពូជស្រូវប្រពៃណី ដែលប៉ះពាល់ដល់ជីវភាពរស់នៅ និងជីវភាពប្រចាំថ្ងៃរបស់ដើមបណ្តឹង។

- ការចុះខ្សោយនៃការផ្គត់ផ្គង់ទឹក និងគុណភាពទឹក៖ ដើមបណ្តឹងបាននិយាយថា ពួកគេមានការលំបាកក្នុងការប្រើប្រាស់ទឹកស្អាតចាប់តាំងពីគម្រោងសេសានក្រោម ២ ចាប់ផ្តើមដំណើរការ។ ក្រៅពីការផ្គត់ផ្គង់ទឹកមានការប្រែប្រួលហើយនោះ ដើមបណ្តឹងបានសង្កេតឃើញថា ទឹកមានភាពល្អក់ និងមើលទៅមិនស្អាត ឬមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់នោះទេ។ បន្ថែមពីនេះទៀត ដើមបណ្តឹងបានកត់សម្គាល់ថា នៅឯកន្លែងតាំងទីលំនៅថ្មី ពួកគេត្រូវទិញទឹក ដែលជាហេតុនាំឱ្យមានការកើនឡើងនូវការចំណាយ និងរួមចំណែកធ្វើឱ្យពួកគេកាន់តែលំបាក។
- បញ្ហាដីធ្លី៖ ដើមបណ្តឹងដែលរស់នៅភូមិក្បាលរមាសចាស់បានសង្កត់ធ្ងន់ថា ពួកគេត្រូវការដីសម្ភូហភាពមួយកន្លែង និងបានពន្យល់ថា ប្រព័ន្ធផ្តល់ប័ណ្ណកម្មសិទ្ធិលក្ខណៈបុគ្គលមិនស្របតាមរបៀបរស់នៅតាមបែបប្រពៃណីរបស់ពួកគេទេ។ ពួកគេក៏បានចង្អុលបង្ហាញផងដែរថា ពួកគេបានស្នើសុំដីសហគមន៍ពីអាជ្ញាធរ ប៉ុន្តែមិនបានទទួលការឆ្លើយតបទេ។ នៅឯកន្លែងតាំងទីលំនៅថ្មី ដើមបណ្តឹងបានអះអាងថា ឧប្បត្តិហេតុបានកើតឡើង ដោយអ្នកខាងក្រៅចូលមកក្នុងដីរបស់ពួកគេដើម្បីសាងសង់ខ្ទម ដោយយកលេសថាបានទិញដីនោះ។
- សិទ្ធិទទួលបានទឹក អគ្គិសនី និងប័ណ្ណកម្មសិទ្ធដីធ្លី៖ គ្រួសារដែលបន្តរស់នៅទីតាំងចាស់ បានចង្អុលបង្ហាញថា ពួកគេចង់ឱ្យលទ្ធភាពទទួលបានទឹក និងអគ្គិសនី ព្រមទាំងសន្តិសុខដីធ្លី មានភាពប្រសើរជាងមុន។

លើសពីនេះទៀត ដើមបណ្តឹងបានបង្ហាញអំពីក្តីកង្វល់បន្ថែមទៀត ដោយសារមានសេចក្តីរាយការណ៍ឱ្យដឹងថា មានគម្រោងសាងសង់ទំនប់បន្ថែមទៀតនៅលើដងទន្លេស្រែពក និងទន្លេសេសាន ហើយពួកគេព្រួយបារម្ភអំពីផលប៉ះពាល់ជាបន្តបន្ទាប់នៃគម្រោងសាងសង់ផ្សេងៗ។

ជារួម ដើមបណ្តឹងបានបញ្ចេញមតិថា ទោះបីជាមានការខិតខំប្រឹងប្រែងរបស់ពួកគេ និងការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីកង្វល់របស់ពួកគេក៏ដោយ ក៏ស្ថានភាពមិនមានភាពប្រសើរឡើងដែរ ហើយពួកគេនៅតែបន្តរងគ្រោះពីផលប៉ះពាល់នៃគម្រោងសេសានក្រោម ២ នេះ។

ដើមបណ្តឹងបានបង្ហាញចំណាប់អារម្មណ៍ចំពោះការចូលរួមក្នុងដំណើរការដោះស្រាយវិវាទដែលសម្របសម្រួលដោយស៊ីអេអូ ជាមួយម្ចាស់គម្រោង ដើម្បីចែករំលែកអំពីកង្វល់របស់ពួកគេដោយផ្ទាល់ និងពិភាក្សាអំពីដំណោះស្រាយដែលអាចមាន ដើម្បីដោះស្រាយផលប៉ះពាល់ទាំងនោះ។

### *ទស្សនៈរបស់ម្ចាស់គម្រោង*

ស៊ីអេអូ បានព្យាយាមទាក់ទង Huaneng Lancang River International Energy ជាម្ចាស់គម្រោងដែល

រងការចោទប្រកាន់ តាមរយៈអ៊ីមែល ទូរសព្ទ ទូរសារ និងប្រៃសណីយ៍[6] ដើម្បីរួមបញ្ចូលទស្សនៈរបស់ពួកគេនៅក្នុងរបាយការណ៍នេះ និងស្វែងយល់អំពីឆន្ទៈរបស់ពួកគេចំពោះការចូលរួមក្នុងដំណើរការដោះស្រាយវិវាទជាមួយដើមបណ្ដឹង ប៉ុន្តែការព្យាយាមទាំងនេះមិនទទួលបានជោគជ័យឡើយ។

### *ទស្សនៈរបស់ PSBC*

PSBC បានបង្ហាញទស្សនៈថា សំណុំរឿងនេះមិនបំពេញតាមលក្ខណវិនិច្ឆ័យលក្ខខណ្ឌសមស្របរបស់ស៊ីអេអូ ដូចមានចែងនៅក្នុងមាត្រា ៤១ នៃគោលនយោបាយស៊ីអេអូ[7]នោះទេ ដោយសារហេតុផលខាងក្រោម៖

១. <u>មិនមានភស្តុតាង ដែលបង្ហាញថាគម្រោងសេសានក្រោម ២ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា "អនុគម្រោង FI" នោះទេ៖</u>

- PSBC បានគូសបញ្ជាក់ថា គោលនយោបាយស៊ីអេអូ បានកំណត់ថា "អនុគម្រោង FI" ជា *"ប្រតិបត្តិការអាជីវកម្មរបស់អតិថិជនបន្ត ក្នុងការប្រើប្រាស់លក្ខខណ្ឌតម្រូវនៃផលបរបរនៅក្នុងឯកសារហិរញ្ញវត្ថុ ឬឯកសារវិនិយោគរបស់ IFC ឬកិច្ចសន្យាធានារបស់ MIGA"* [8] ហើយស៊ីអេអូបានរកឃើញនៅក្នុងសំណុំរឿងមុនៗ[9] ថា៖ *"ក្នុងការសម្រេចចិត្តថាតើសកម្មភាពអាជីវកម្មដែលជាកម្មវត្ថុនៃពាក្យបណ្ដឹងរបស់ស៊ីអេអូ មាន ឬគ្មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជា 'ប្រតិបត្តិការអាជីវកម្ម' នៃអតិថិជនបន្តរបស់ IFC ដែលជាហេតុនាំឱ្យវាក្លាយជាអនុគម្រោងមួយ ស៊ីអេអូពិចារណាទាំងការពាក់ព័ន្ធរបស់អតិថិជនបន្តនៅក្នុងប្រតិបត្តិការអាជីវកម្ម និងការប្រើប្រាស់ប្រតិបត្តិការនៃសកម្មភាពអាជីវកម្មនោះ ព្រមទាំងសារសំខាន់នៃសកម្មភាពអាជីវកម្មចំពោះអតិថិជនបន្ត។*

---

[6] កាលពីខែមីនា និងមេសា ឆ្នាំ២០២៤ ស៊ីអេអូ បានផ្ញើអ៊ីមែលទៅអាសយដ្ឋានអ៊ីមែលផ្សេងៗគ្នាចំនួន៥ ព្រមទាំងលិខិតទៅអាសយដ្ឋានផ្សេងៗគ្នាចំនួន៣ សម្រាប់ការិយាល័យកណ្ដាលរបស់ក្រុមហ៊ុន Huaneng Lancang River International Energy Co. Ltd និង Huaneng Group។ លិខិតទាំងនោះក៏ត្រូវបានផ្ញើតាមទូរសារទៅលេខទូរសារចំនួន២ផ្សេងគ្នាផងដែរ។ ស៊ីអេអូ ក៏បានខិតខំទាក់ទងទៅ Huaneng Group តាមទូរស័ព្ទជាច្រើនដងដែរ។ ការខិតខំទាំងនេះមិនទទួលបានជោគជ័យឡើយ។ បន្ថែមពីនេះទៀត ស៊ីអេអូ បានទាក់ទងទៅអ្នកដែលមានចំណែកពាក់ព័ន្ធជាច្រើន ដើម្បីស្នើសុំការគាំទ្រពីពួកគេឱ្យជួយគាំទ្រដល់ការភ្ជាប់ទំនាក់ទំនងជាមួយ Huaneng ប៉ុន្តែមិនទទួលបានជោគជ័យ។

[7] គោលនយោបាយស៊ីអេអូ៖ https://www.cao-ombudsman.org/sites/default/files/documents/CAO%20Policy/ifc-miga-independent-accountability-mechanism-cao-policy.pdf

[8] សូមមើលគោលនយោបាយស៊ីអេអូ សទ្ទានុក្រម៖ https://www.cao-ombudsman.org/sites/default/files/documents/CAO%20Policy/ifc-miga-independent-accountability-mechanism-cao-policy.pdf

[9] សូមមើលការវាយតម្លៃអំពីភាពអនុលោមរបស់ស៊ីអេអូលើពាក្យបណ្ដឹង ដែលពាក់ព័ន្ធនឹងការផ្ដល់កម្ចីរបស់ IFC ទៅកាន់ Dairi Prima Mineral Mine នៅប្រទេសឥណ្ឌូនេស៊ី តាមរយៈការវិនិយោគនៅក្នុងធនាគារ Postal Savings Bank of China (PSBC) ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២២ ទំ. ២៩៖ https://www.cao-ombudsman.org/sites/default/files/downloads/CAO_Compliance_Appraisal%20Report_PSBC_Indonesia_July_2022_EN.pdf និងការវាយតម្លៃពាក្យបណ្ដឹងរបស់ស៊ីអេអូ ពាក់ព័ន្ធនឹងការផ្ដល់កម្ចីរបស់ IFC ដល់គម្រោងវារីអគ្គិសនីសេសានក្រោម ២ នៅប្រទេសកម្ពុជា តាមរយៈ ABBank និង Vietinbank ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ ទំ. ១៦៖ https://www.cao-ombudsman.org/sites/default/files/downloads/CAO_Compliance%20Appraisal%20Report_Cambodia%20FI%2001-3_December%202022_EN.pdf

- យោងតាម PSBC គម្រោងសេសានក្រោម ២ មិន *"ស្ថិតក្នុងការប្រើប្រាស់លក្ខខណ្ឌតម្រូវនៃផលរបរនៅក្នុងឯកសារហិរញ្ញវត្ថុ ឬឯកសារវិនិយោគរបស់ IFC នោះទេ"* ពីព្រោះផលរបរពីប្រាក់កម្ចីទាំងពីរ ដែលផ្ដល់ដោយ PSBC ដល់ក្រុមហ៊ុន Huaneng Lancang River Hydropower Co., Ltd. ("Huaneng") ត្រូវបានប្រើប្រាស់សម្រាប់ការសាងសង់គម្រោងស្ថានីយ៍វារីអគ្គិសនី Huangdeng និងគម្រោងស្ថានីយ៍វារីអគ្គិសនី Miaowei <u>ទាំងស្រុង</u> នៅក្នុងសាធារណរដ្ឋប្រជាមានិតចិន ដូចបានចង្អុលបង្ហាញយ៉ាងច្បាស់នៅក្នុងកិច្ចព្រមព្រៀងផ្ដល់ប្រាក់កម្ចី។
- យោងតាម PSBC ការសម្រេចចិត្តរបស់ស៊ីអេអូថាមានលក្ខខណ្ឌសមស្រប គឺធ្វើឡើងដោយគ្មានមូលដ្ឋាន និងមានមន្ទិល ពីព្រោះវាបានធ្វើឡើងដោយផ្អែកលើការសន្មតជាមុន ដោយពុំមានព័ត៌មានអំពី *"ការពាក់ព័ន្ធ និងឥទ្ធិពល"* របស់ "អតិថិជនបន្ត"។ PSBC បានកត់សម្គាល់ថា ពួកគេរកមិនឃើញខ្លឹមសារពាក់ព័ន្ធណាមួយនៅក្នុងពាក្យបណ្ដឹង ដែល ស៊ីអេអូ បានចែករំលែកជាមួយពួកគេ ហើយស៊ីអេអូ ក៏មិនផ្ដល់ព័ត៌មានណាមួយជូនដល់ពួកគេ ពាក់ព័ន្ធនឹងបញ្ហានេះដែរ។

២. <u>មិនមានភស្តុតាង ដែលថា Huaneng គឺជា "អតិថិជនបន្ត" "សកម្ម" របស់ IFC នោះទេ</u>

PSBC បានអះអាងអំពីការពិតថា ការដែលគេបានផ្ដល់កម្ចីទៅឱ្យក្រុមហ៊ុន Huaneng Lancang River Hydropower មិនមានន័យថា Huaneng Lancang River Hydropower (ឬ Huaneng Lancang River International Energy ដែលជាបុត្រសម្ព័ន្ធដែលខ្លួនជាម្ចាស់ទាំងស្រុង) មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាអតិថិជនបន្ត "សកម្ម" របស់ IFC ដែលគេយល់ថាជាលក្ខខណ្ឌតម្រូវនៅក្រោមមាត្រា ៤១ នៃគោលនយោបាយរបស់ ស៊ីអេអូ នោះទេ។

យោងតាម PSBC ស៊ីអេអូមិនបានខិតខំប្រឹងប្រែងប្រមូលព័ត៌មានអំពីបញ្ហានេះឡើយ។ PSBC បានចង្អុលបង្ហាញថា ស៊ីអេអូមិនបានទាក់ទងពួកគេដើម្បីសាកសួរអំពីបញ្ហានេះ ក្នុងអំឡុងពេលនៃដំណើរការកំណត់លក្ខខណ្ឌសមស្របនេះទេ។ PSBC បានបង្ហាញអំពីការភ័ន្តច្រឡំ និងការខកចិត្តរបស់ពួកគេចំពោះការអនុវត្តរបស់ស៊ីអេអូ ដែលមិនបានទាក់ទងអតិថិជន IFC ដោយផ្ទាល់ ក្នុងអំឡុងពេលដំណើរការត្រួតពិនិត្យលក្ខខណ្ឌសមស្របនោះ ហើយធ្វើការតែតាមរយៈ IFC ប៉ុណ្ណោះ។ ពួកគេបានបន្ថែមទៀតថា ពួកគេមានអារម្មណ៍ថា ស៊ីអេអូបានធ្វើការសម្រេចចិត្តអំពីលក្ខខណ្ឌសមស្រប ដោយផ្អែកលើការសន្មតជាមុន ជាជាងព័ត៌មានជាក់ស្ដែង។

៣. <u>មិនមានភស្តុតាងដែលបង្ហាញថា "ទំនាក់ទំនងរវាងអតិថិជន FI និងអតិថិជនបន្តសកម្មរបស់ខ្លួន" "មានមានលក្ខខណៈគួរឱ្យកត់សម្គាល់" នោះទេ</u>

យោងតាម PSBC ស៊ីអេអូ ប្រមូលព័ត៌មានបានតិចតួចបំផុតអំពីទំនាក់ទំនងផ្នែកហិរញ្ញវត្ថុ ដែលដើមបណ្ដឹងបានចោទប្រកាន់ ហើយក្នុងករណីបែបនេះ ស៊ីអេអូ មិនត្រូវកំណត់ថា ទំនាក់ទំនងរវាងអតិថិជន FI និងអតិថិជនបន្ត "មានលក្ខណៈគួរឱ្យកត់សម្គាល់" ដែលជាលក្ខខណ្ឌតម្រូវមួយ នៅក្រោមមាត្រា ៤១ នៃគោលនយោបាយរបស់ស៊ីអេអូនោះទេ។ យោងតាម PSBC បានឱ្យដឹងថា ការអនុវត្តបែបនេះផ្ទុយទៅនឹងស្មារតី និងលិខិតនៃមាត្រា ៤១ នៃគោលនយោបាយរបស់ ស៊ីអេអូ ព្រមទាំងអនុសាសន៍នៃរបាយការណ៍ស្ដីពី *ការពិនិត្យពីខាងក្រៅ*

*ទៅលើគណនេយ្យភាពផ្នែកបរិស្ថាន និងសង្គមរបស់ IFC's / MIGA's រួមទាំងតួនាទីនិងប្រសិទ្ធភាពរបស់ ស៊ីអេអូ៖ របាយការណ៍ និងអនុសាសន៍* ចេញថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០២០។[10]

PSBC បានគូសបញ្ជាក់ថា របាយការណ៍ស្តីពីការត្រួតពិនិត្យពីខាងក្រៅ បានសង្កត់ធ្ងន់ថា "ភាគហ៊ុន ប្រភេទ និងទម្រង់ នៃការវិនិយោគរបស់ FI នៅក្នុងអនុគម្រោង ធ្វើឱ្យការវិនិយោគមានលក្ខណៈគួរឱ្យកត់សម្គាល់" និងបានអះអាងថា គោលនយោបាយរបស់ ស៊ីអេអូ ហាក់បីដូចជាបានអនុម័តទៅលើយោបល់នេះ នៅក្នុងមាត្រា ៤១ របស់ខ្លួន ដែលពិចារណាជាក់លាក់អំពីការកំណត់ថាមានលក្ខខណ្ឌសមស្របរបស់ពាក្យបណ្ដឹងដែលពាក់ព័ន្ធទៅនឹងអន្តរការីហិរញ្ញវត្ថុ។ បើទោះជាដូច្នេះក្តី យោងតាម PSBC បានឱ្យដឹងថា បញ្ញត្តិនៃមាត្រា ៤១ មិនត្រូវបានយកមកអនុវត្តឱ្យបានគ្រប់គ្រាន់នៅត្រង់នេះឡើយ អាស្រ័យដោយយោងតាមការយល់ឃើញរបស់ពួកគេ ស៊ីអេអូ បានសន្មតជាមុនរួចទៅហើយថាមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ទាំងអស់ បើទោះបីជាព័ត៌មានពាក់ព័ន្ធនឹងចរិកលក្ខណៈ "គួរឱ្យកត់សម្គាល់" នៃទំនាក់ទំនងហិរញ្ញវត្ថុ នៅមានកម្រិត និងពុំមានការវិភាគ ឬកិច្ចពិភាក្សាបន្ថែមត្រូវបានធ្វើឡើងក៏ដោយ។

លើសពីនេះទៀត នៅខណៈពេលដែល PSBC បង្ហាញកង្វល់របស់ពួកគេអំពីបញ្ហាដែលបានលើកឡើងដោយដើមបណ្ដឹងនោះ ពួកគេបានពន្យល់ថា ពួកគេខ្វះឥទ្ធិពលចាំបាច់ ដើម្បីជួយសម្រួលដល់ការដោះស្រាយបញ្ហានោះ ដោយសារប្រាក់កម្ចីដែល PSBC ផ្តល់ទៅ Huaneng Lancang River Hydropower សម្រាប់គោលបំណងដទៃទៀត ត្រូវបានសងវិញគ្រប់ចំនួនហើយ។ ពួកគេក៏បានចង្អុលបង្ហាញផងដែរថា IFC បានដកខ្លួនចេញពី PSBC ក្នុងខែធ្នូ ឆ្នាំ២០២៣ ដូច្នេះពួកគេមិនអាចបន្តមានឥទ្ធិពលណាមួយ តាមរយៈ PSBC លើប្រតិបត្តិការនៃគម្រោងសេសានក្រោម ២ ទៀតទេ។

ជាចុងក្រោយ PSBC បានកត់សម្គាល់ថាមានសំណុំរឿងរបស់ស៊ីអេអូ ដែលមានស្រាប់ នៅក្នុងការស៊ើបអង្កេតអំពីភាពអនុលោម ទាក់ទងនឹងគម្រោងសេសានក្រោម ២ [11] និងបានបង្ហាញទស្សនៈរបស់ពួកគេថា សំណុំរឿងបែបនេះគឺគ្រប់គ្រាន់ក្នុងការសម្រេចគោលបំណងរបស់ស៊ីអេអូ ក្នុងការជួយដោះស្រាយបញ្ហាដែលបានលើកឡើងអំពី *"ផលប៉ះពាល់បរិស្ថាន និង/ឬសង្គមនៃគម្រោង និង/ឬអនុគម្រោង"* និងស្វែងរកគណនេយ្យភាពពី IFC។ គេក៏បានបញ្ជាក់ជាក់លាក់ផងដែរថា គេមិនទាន់បានទទួលពាក្យបណ្ដឹងដែលបានដាក់ ក្នុងឆ្នាំ២០១៨ នៅឡើយទេ ដូច្នេះគេមិនអាចបង្ហាញអំពីខ្លឹមសារមួយចំនួននៅក្នុងផ្នែកដែលនិយាយអំពី "ទស្សនៈរបស់ដើមបណ្ដឹង" ដែលសំដៅចំពោះពាក្យបណ្ដឹងនេះឡើយ។

## 4. សេចក្តីសន្និដ្ឋានអំពីការវាយតម្លៃ

ក្នុងអំឡុងពេលដំណើរការវាយតម្លៃ ដើមបណ្ដឹងបានសម្ដែងចំណាប់អារម្មណ៍ចំពោះការចូលរួមក្នុងដំណើរការដោះស្រាយវិវាទ ដែលសម្របសម្រួលដោយស៊ីអេអូ ជាមួយម្ចាស់គម្រោង ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្ដឹង។ PBSC បានចង្អុលបង្ហាញថា ពួកគេមិនជំទាស់នឹងស៊ីអេអូ ក្នុងការសម្របសម្រួលកិច្ចសន្ទនារវាងដើមបណ្ដឹង និងម្ចាស់គម្រោងសេសានក្រោម ២ នោះទេ។ ស៊ីអេអូបានព្យាយាមជា

[10] https://www.worldbank.org/en/about/leadership/brief/external-review-of-ifc-miga-es-accountability
[11] https://www.cao-ombudsman.org/cases/cambodia-financial-intermediaries-01-03

ច្រើនលើក ក្នុងការទាក់ទងទៅក្រុមហ៊ុន Huaneng Lancang River International Energy ជាម្ចាស់គម្រោង ដែលរងការចោទប្រកាន់ ប៉ុន្តែការព្យាយាមទាំងនេះមិនទទួលបានជោគជ័យឡើយ។

ហេតុនេះ និងដោយស្របទៅតាមគោលនយោបាយរបស់ ស៊ីអេអូ នៅពេលនេះ សំណុំរឿងនេះនឹងត្រូវផ្ទេរទៅមុខងារត្រួតពិនិត្យភាពអនុលោមរបស់ ស៊ីអេអូ។ ការចោទប្រកាន់ថា IFC មានទំនាក់ទំនងទៅនឹងគម្រោងសេសានក្រោម ២ តាមរយៈ PSBC និងបញ្ហាភាពអនុលោមដែលពាក់ព័ន្ធ នឹងត្រូវបានត្រួតពិនិត្យបន្ថែមទៀតអំពីភាពពាក់ព័ន្ធ នៅក្នុងបរិបទនៃការវាយតម្លៃភាពអនុលោមដោយ ស៊ីអេអូ ប៉ុន្តែចំណុចនេះហួសពីវិសាលភាពនៃដំណើរការវាយតម្លៃរបស់ ស៊ីអេអូ។

## សេចក្តីបន្ថែម ក៖ ដំណើរការដោះស្រាយបណ្តឹងរបស់ការិយាល័យ ស៊ីអេអូ

នៅពេលដែលការិយាល័យ ស៊ីអេអូ ប្រកាសថាពាក្យបណ្តឹងមួយមានលក្ខខណ្ឌសមស្របអាចទទួលយកបាន មុខងារផ្នែកដោះស្រាយវិវាទ នៃការិយាល័យ ស៊ីអេអូ នឹងចុះធ្វើការប៉ាន់ប្រមាណបឋមមួយ។ ការប៉ាន់ប្រមាណរបស់ការិយាល័យ ស៊ីអេអូ មានគោលបំណង៖ (១) បញ្ជាក់អំពីបញ្ហា និងកង្វល់ដែល ដើមបណ្តឹងបានលើកឡើង (២) ប្រមូលព័ត៌មានអំពីការយល់ឃើញរបស់អ្នកពាក់ព័ន្ធដទៃទៀតចំពោះស្ថានភាព និង (៣) ជួយឱ្យអ្នកពាក់ព័ន្ធយល់អំពីជម្រើសឧបាស្រ័យ ឬ ដំណោះស្រាយ ដែលមានសម្រាប់ ពួកគេ និង សម្រេចថាតើពួកគេមានបំណងចង់ចូលរួមនៅក្នុងដំណោះស្រាយបែបសហការមួយ តាមរយៈ មុខងារដោះស្រាយវិវាទរបស់ការិយាល័យ ស៊ីអេអូ ឬ ថាតើសំណុំរឿងនោះគួរត្រូវបានត្រួតពិនិត្យដោយមុខងារ ផ្នែកត្រួតពិនិត្យភាពអនុលោម នៃការិយាល័យ ស៊ីអេអូ។

យោងតាមគោលនយោបាយនៃយន្តការគណនេយ្យភាពឯករាជ្យរបស់ IFC/MIGA (ការិយាល័យ ស៊ីអេអូ) [12] ជំហានខាងក្រោមត្រូវបានអនុវត្តតាមជាទូទៅ ដើម្បីឆ្លើយតបទៅនឹងពាក្យបណ្តឹងដែលទទួលបាន៖

ជំហានទី១៖ **ការបញ្ជាក់**ថាបានទទួលពាក្យបណ្តឹង។

ជំហានទី២៖ **លក្ខខណ្ឌសមស្របដែលអាចទទួលយកបាន។** ការកំណត់ថាតើពាក្យបណ្តឹងមានលក្ខខណ្ឌសមស្របអាចទទួលយកបានដែរឬទេ ដើម្បីធ្វើការប៉ាន់ប្រមាណក្រោមអាណត្តិការងាររបស់ការិយាល័យ ស៊ីអេអូ (មិនឱ្យលើសពីរយៈពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ)។

ជំហានទី៣៖ **ការប៉ាន់ប្រមាណ**៖ ការប៉ាន់ប្រមាណទៅលើបញ្ហា និងការផ្តល់កិច្ច គាំទ្រជូនដល់អ្នកពាក់ព័ន្ធក្នុងការស្វែងយល់ និងការកំណត់ ថាតើពួកគេមានបំណងចង់ចូលរួមនៅក្នុងដំណោះស្រាយដែលមានការព្រមព្រៀងគ្នា តាមរយៈដំណើរការបែបសហការមួយ ដែលផ្តួចផ្តើមឡើងដោយមុខងារផ្នែកដោះស្រាយវិវាទ នៃការិយាល័យ ស៊ីអេអូ ឬ សំណុំរឿងនេះគប្បីត្រូវបានដោះស្រាយដោយមុខងារផ្នែកត្រួតពិនិត្យភាពអនុលោម នៃការិយាល័យ ស៊ីអេអូ ដើម្បីពិនិត្យឡើងវិញទៅលើការយកចិត្តទុកដាក់ប្រុងប្រយ័ត្នខ្ពស់ របស់ IFC/MIGA លើផ្នែកបរិស្ថាន និង សង្គម។ ការប៉ាន់ប្រមាណ អាចមានរយៈពេលអតិបរមា រហូតដល់ ៩០ថ្ងៃ នៃថ្ងៃធ្វើការ និងអាចពន្យារពេលបន្ថែមទៀត ច្រើនបំផុតត្រឹម ៣០ថ្ងៃ នៃថ្ងៃធ្វើការ ប្រសិនបើក្រោយរយៈពេល ៩០ថ្ងៃ នៃថ្ងៃធ្វើការ៖ (១) ភាគីបញ្ជាក់ថាទំនងអាចមានដំណោះស្រាយចំពោះបណ្តឹង ឬ (២) ភាគីណាមួយបង្ហាញអំពីចំណាប់អារម្មណ៍ចំពោះការដោះស្រាយវិវាទ និង មានសក្តានុពលដែលភាគីម្ខាងទៀតនឹងឯកភាព។

ជំហានទី៤៖ ការសម្របសម្រួលដោះស្រាយ៖ ប្រសិនបើគូភាគីជ្រើសរើសចូលរួមនៅក្នុងដំណើរការបែបសហការ ពេលនោះមុខងារផ្នែកដោះស្រាយវិវាទ នៃការិយាល័យ ស៊ីអេអូ នឹងត្រូវផ្តួចផ្តើមឡើង។ ជាទូទៅ ដំណើរការដោះស្រាយវិវាទមានមូលដ្ឋានផ្អែកលើ ឬ ផ្តួចផ្តើមដោយអនុស្សរណៈនៃការ

[12] សម្រាប់សេចក្តីលម្អិតបន្ថែមអំពីតួនាទី និងការងាររបស់ការិយាល័យ ស៊ីអេអូ សូមអានគោលនយោបាយនៃយន្តការ គណនេយ្យភាពឯករាជ្យរបស់ IFC/MIGA (CAO): https://documents.worldbank.org/en/publication/documents-reports/documentdetail/889191625065397617/ifc-miga-independent-accountability-mechanism-cao-policy

យោគយល់គ្នាមួយ និង/ឬ វិធានមូលដ្ឋានដែលមានការឯកភាពព្រមព្រៀងគ្នា រវាងគូភាគី។ ដំណើរការនេះអាចពាក់ព័ន្ធការងារសម្របសម្រួល/សន្ទានកម្ម ការរួមគ្នាស្វែងរកការពិត ឬ អភិក្រមដំណោះស្រាយដទៃទៀតដែលមានការឯកភាពព្រមព្រៀងគ្នា ដែលនាំឱ្យឈានទៅសម្រេចបាននូវកិច្ចព្រមព្រៀងដោះស្រាយបញ្ហា ឬ គោលដៅដទៃទៀតដែលមានការឯកភាពព្រមព្រៀងគ្នា និង គោលដៅដែលមានលក្ខណៈសមស្រប។ គោលបំណងចម្បងនៃប្រភេទអភិក្រមដោះស្រាយបញ្ហាទាំងនេះ គឺដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ព្រមទាំងបញ្ហាគួរឱ្យកត់សម្គាល់ដទៃទៀត ពាក់ព័ន្ធទៅនឹងពាក្យបណ្តឹង ដែលត្រូវបានកំណត់រកឃើញក្នុងអំឡុងពេលប៉ាន់ប្រមាណ ឬ ដំណើរការដោះស្រាយវិវាទ ក្នុងលក្ខណៈមួយដែលអាចទទួលយកបានចំពោះភាគីរងផលប៉ះពាល់។[13]

ឬ

**ការវាយតម្លៃ/ការស៊ើបអង្កេតទៅលើភាពអនុលោម៖** ប្រសិនបើគូភាគីជ្រើសរើសយកដំណើរការស៊ើបអង្កេត ពាក្យបណ្តឹងត្រូវបានបញ្ជូនទៅមុខងារត្រួតពិនិត្យភាពអនុលោមរបស់ការិយាល័យ ស៊ីអេអូ។ ពាក្យបណ្តឹងក៏ ត្រូវបានបញ្ជូនទៅមុខងារត្រួតពិនិត្យភាពអនុលោមផងដែរ នៅពេលដែលដំណើរការដោះស្រាយវិវាទ នាំឱ្យទទួលបានការឯកភាពព្រមព្រៀងមួយផ្នែក ឬ គ្មានការឯកភាពព្រមព្រៀងទាល់តែសោះ។ យ៉ាងហោចណាស់ ត្រូវមានដើមបណ្តឹងណាម្នាក់ ដែលត្រូវផ្តល់ការយល់ព្រមជាក់លាក់ សម្រាប់ការផ្ទេរនេះ លើកលែងតែ ការិយាល័យ ស៊ីអេអូ បានដឹងអំពីបញ្ហាកង្វល់ពាក់ព័ន្ធនឹងការគំរាមកំហែង និង ការសងសឹក។ មុខងារត្រួតពិនិត្យភាពអនុលោមរបស់ការិយាល័យ ស៊ីអេអូ ពិនិត្យទៅលើភាពអនុលោមរបស់ IFC/MIGA ទៅនឹង គោលនយោបាយបរិស្ថាន និងសង្គម ប៉ាន់ប្រមាណអំពីគ្រោះថ្នាក់ដែលពាក់ព័ន្ធ និង ផ្តល់អនុសាសន៍អំពីសកម្មភាពកែតម្រូវ ក្នុងករណីសមស្រប ក្រោយពេលបញ្ចប់ដំណើរការមួយដែលមានបីជំហាន។ ទី១ ការវាយតម្លៃទៅលើភាពអនុលោម កំណត់ថាតើត្រូវធ្វើការស៊ើបអង្កេតបន្ថែមទៀត ដែរឬទេ។ ការវាយតម្លៃនេះ អាចចំណាយពេលរហូតដល់ ៤៥ថ្ងៃ នៃថ្ងៃធ្វើការ និង អាចពន្យារពេលបន្ថែមទៀតត្រឹមរយៈពេល ២០ថ្ងៃ នៃថ្ងៃធ្វើការ ក្នុងករណីពិសេស។ ទី២ ប្រសិនបើត្រូវធ្វើការស៊ើបអង្កេត គេត្រូវស៊ើបអង្កេតស៊ីជម្រៅទៅលើភាពអនុលោមនៃសមិទ្ធកម្មរបស់ IFC/MIGA បន្ទាប់ពីការវាយតម្លៃនេះ។ របាយការណ៍ស៊ើបអង្កេតមួយនឹងផ្សព្វផ្សាយជាសាធារណៈ ព្រមជាមួយនឹងការឆ្លើយតបរបស់ IFC/MIGA និង ផែនការសកម្មភាពមួយ ដើម្បីដោះស្រាយ បញ្ហាគំហើញអំពីភាពមិន

[13] ក្នុងករណីដែលអ្នកពាក់ព័ន្ធមិនអាចដោះស្រាយបញ្ហាបាន តាមរយៈដំណើរការបែបសហការ នៅក្នុងក្របខ័ណ្ឌពេលវេលាមួយដែលបានឯកភាពគ្នា ជាដំបូង ការដោះស្រាយវិវាទរបស់ការិយាល័យ ស៊ីអេអូ នឹងខិតខំជួយដល់អ្នកពាក់ព័ន្ធក្នុងការទម្លាយភាពជាប់គាំង នានា។ ប្រសិនបើសកម្មភាពនេះមិនអាចទៅរួច ក្រុមការងារដោះស្រាយវិវាទនឹងជូនដំណឹងដល់អ្នកពាក់ព័ន្ធ រួមទាំងបុគ្គលិករបស់ IFC/MIGA ប្រធាន និង ក្រុមប្រឹក្សាភិបាលនៃក្រុមធនាគារពិភពលោក និង សាធារណជនថា ផ្នែកដោះស្រាយវិវាទនៃការិយាល័យ ស៊ីអេអូ បានបិទពាក្យបណ្តឹងនេះ និង ផ្ទេរទៅឱ្យផ្នែកត្រួតពិនិត្យភាពអនុលោម នៃការិយាល័យ ស៊ីអេអូ ដើម្បីវាយតម្លៃ។

អនុលោម និង គ្រោះថ្នាក់ពាក់ព័ន្ធ។ ទី៣ ក្នុងករណីរកឃើញមានភាពមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ ការិយាល័យ ស៊ីអេអូ នឹងត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពឱ្យមានប្រសិទ្ធភាព។

ជំហានទី៥៖ **ការត្រួតពិនិត្យ និងតាមដាន។**

ជំហានទី៦៖ **សេចក្តីសន្និដ្ឋាន/ការបិទសំណុំរឿង។**